ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៨ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៣ មាត្រា១៥ មាត្រា១៦ និងមាត្រា១៧ នៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងជានាំនូវការផ្ទេរមុខងារនិងធនធាននានាពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានលក្ខណៈជាប្រព័ន្ធតាមដំណាក់កាល មានសនិទានភាព ការសម្របសម្រួល ការពិគ្រោះយោបល់ តម្លាភាព និងប្រកបដោយសមធម៌ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីដំណើរការទូទៅនិងពេលវេលានៃការរៀបចំផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការផ្ទេរមុខងារនិងធនធាននានាពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសនៅក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ៖

- **មុខងារ** សំដៅដល់អំពើឬសកម្មភាពដែលរាប់បញ្ចូលទាំងការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយផ្សេងៗទៀត។

- **ធនធាន** សំដៅដល់ទ្រព្យសម្បត្តិ ហិរញ្ញវត្ថុ ចំណូល បុគ្គលិក និងសមត្ថភាព។
- **ក្រុមប្រឹក្សា** សំដៅដល់ ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់។
- **ទ្រព្យសម្បត្តិ** សំដៅដល់គ្រឿងម៉ាស៊ីន យានយន្ត ឧបករណ៍ គ្រឿងសង្ហារិម សម្ភារៈ ការិយាល័យ លិខិតស្នាម ឯកសារ និងដីសាធារណៈ អចលនទ្រព្យសាធារណៈ សំណង់សាធារណៈ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជា ស្ពាន អគារ ព្រៃក ផ្លូវ ឬវត្ថុប្រហាក់ប្រហែលគ្នានេះ។
- **រដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
- **មុខងារជាកាតព្វកិច្ច** សំដៅដល់មុខងារដែលត្រូវបានគ្រប់គ្រង ចាត់ចែង និងអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិអនុលោមទៅតាមបទដ្ឋាននិងនីតិវិធីដែលកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬលិខិតបទដ្ឋានគតិយុត្តនានា។
- **មុខងារជាជម្រើស** សំដៅដល់មុខងារដែលមិនមានលក្ខណៈជាកាតព្វកិច្ច ហើយរដ្ឋបាលថ្នាក់ក្រោមជាតិអាចជ្រើសរើសអនុវត្តឬមិនអនុវត្ត។
- **ផ្ទេរ** សំដៅដល់ការប្រគល់ឬការធ្វើប្រតិភូកម្មមុខងារ។
- **ការប្រគល់មុខងារ** សំដៅដល់ការផ្ទេរភាពជាម្ចាស់នៃមុខងារ ការទទួលខុសត្រូវ អំណាច និងធនធានសិទ្ធិទាំងអស់ដែលចាំបាច់ដើម្បីគ្រប់គ្រងនិងអនុវត្តមុខងារ។
- **ប្រតិភូកម្មមុខងារ** សំដៅដល់ការផ្ទេរនូវមុខងារ ការទទួលខុសត្រូវ អំណាច និងធនធានសិទ្ធិដើម្បីគ្រប់គ្រងនិងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្មនៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្ម។
- **ការផ្ទេរដែលមានលក្ខណៈជាប្រព័ន្ធ** សំដៅដល់ការផ្ទេរមុខងារដែលត្រូវភ្ជាប់មកជាមួយនូវការផ្ទេរធនធានសមស្រប។

## ជំពូកទី២
## ដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធាន
### ផ្នែកទី១
### គោលការណ៍

**មាត្រា ៥.-**

ការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងជាដំណាក់កាល មានសនិទានភាព លក្ខណៈជាប្រព័ន្ធ ការសម្របសម្រួល ការពិគ្រោះយោបល់ ផែនការ តម្លាភាព និងប្រកបដោយសមធម៌។

**មាត្រា ៦.-**

ការពិនិត្យមើលមុខងារឡើងវិញ ត្រូវផ្តល់អាទិភាពចំពោះកិច្ចការចាំបាច់ដែលជះឥទ្ធិពលដោយផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រ ការកែលម្អគុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាន។

**មាត្រា ៧.-**

ការផ្ទេរមុខងារតាមរយៈការប្រគល់ឬការធ្វើប្រតិភូកម្ម ត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍ដូចខាងក្រោម៖

- ស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- អាចគ្រប់គ្រងនិងអនុវត្តបានប្រកបដោយប្រសិទ្ធភាពនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- បម្រើឬផ្តល់ផលប្រយោជន៍ជាចម្បងដល់ប្រជាជននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និង
- មានផលប៉ះពាល់ជាចម្បងនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

ការផ្ទេរមុខងារតាមរយៈការប្រគល់ឬការធ្វើប្រតិភូកម្ម ត្រូវធ្វើឡើងដោយធានាថា៖

- ការផ្ទេរមុខងារត្រូវផ្សារភ្ជាប់ជាមួយការផ្ទេរធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានផ្សេងទៀតដែលចាំបាច់និងសមស្រប
- មានតម្លាភាព ការពិគ្រោះយោបល់ និងការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងតំណាងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលមុខងារ ដោយមានការសម្របសម្រួលពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សរសេរជាអក្សរកាត់ថា "**គ.ជ.អ.ប.**" អនុគណៈកម្មាធិការមុខងារនិងធនធាន និងលេខាធិការដ្ឋាន **គ.ជ.អ.ប.** និង
- មានការរំខានជាអប្បបរមាទៅលើប្រតិបត្តិការដែលកំពុងដំណើរការរបស់រាជរដ្ឋាភិបាល។

**មាត្រា ៨.-**

**គ.ជ.អ.ប.** ត្រូវពិនិត្យមើលឡើងវិញនូវការទទួលខុសត្រូវនិងមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីកំណត់មុខងារនិងធនធានសម្រាប់ផ្ទេរឲ្យទៅដល់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ។

**មាត្រា ៩.-**

**គ.ជ.អ.ប.** ដោយមានជំនួយពីអនុគណៈកម្មាធិការមុខងារនិងធនធាន និងលេខាធិការដ្ឋាន **គ.ជ.អ.ប.** ត្រូវដឹកនាំសម្របសម្រួល គាំទ្រ និងតាមដានកិច្ចដំណើរការផ្ទេរមុខងារនិងធនធានដែលអនុវត្តដោយក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

## ផ្នែកទី២
## ការរៀបចំបញ្ជីវិភាគមុខងារ

**មាត្រា ១០.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំបញ្ជីវិភាគមុខងារ ដើម្បីកំណត់ពី៖

- មុខងារទាំងអស់ដែលកំពុងអនុវត្តជាក់ស្តែងនិងអង្គភាពដែលគ្រប់គ្រងនិងទទួលខុសត្រូវលើការអនុវត្តមុខងារទាំងនេះ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្របខ័ណ្ឌច្បាប់ជាមូលដ្ឋានសម្រាប់បំពេញមុខងារទាំងនេះ
- ធនធានហិរញ្ញវត្ថុជាក់ស្តែងនាពេលបច្ចុប្បន្នដែលបានប្រើប្រាស់ដើម្បីអនុវត្តមុខងារទាំងនេះ
- ធនធានមនុស្សជាក់ស្តែងនាពេលបច្ចុប្បន្នដែលទទួលខុសត្រូវក្នុងការអនុវត្តមុខងារទាំងនេះ និង
- មធ្យោបាយ សម្ភារៈ បរិក្ខារ និងធនធានផ្សេងទៀតដែលចាំបាច់សម្រាប់អនុវត្តមុខងារទាំងនេះ។

**មាត្រា ១១.-**

**គ.ជ.អ.ប.** ត្រូវចេញសេចក្តីណែនាំស្តីពីការរៀបចំបញ្ជីវិភាគមុខងារ សម្រាប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ធ្វើជាមូលដ្ឋានក្នុងការរៀបចំបញ្ជីវិភាគមុខងាររបស់ខ្លួន។

បន្ទាប់ពីបានរៀបចំបញ្ជីវិភាគមុខងាររបស់ខ្លួន ក្រសួង ស្ថាប័នត្រូវធ្វើរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងារនេះ ជូន **គ.ជ.អ.ប.** ដើម្បីពិនិត្យនិងសម្រេច។

## ផ្នែកទី៣
## ការពិនិត្យមើលមុខងារឡើងវិញ

**មាត្រា ១២.-**

បន្ទាប់ពីទទួលបានការឯកភាពពី **គ.ជ.អ.ប.** លើរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងារ ក្រសួង ស្ថាប័ន ត្រូវពិនិត្យមើលឡើងវិញនូវមុខងារ ធនធាន លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការទទួលខុសត្រូវក្នុងការអនុវត្តមុខងារ ដើម្បីកំណត់អំពីមុខងារ និងធនធាន ដែលត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ១៣.-**

ការពិនិត្យមើលមុខងារឡើងវិញ ត្រូវធ្វើឡើងស្របទៅនឹង៖

- មាត្រា២១៥ដល់មាត្រា២២១នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- របាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងារដែលបានឯកភាពដោយ **គ.ជ.អ.ប.**
- គោលការណ៍នានាដែលមានចែងនៅក្នុងមាត្រា៥ មាត្រា៦ និងមាត្រា៧នៃអនុក្រឹត្យនេះ និង
- សេចក្តីសម្រេចនិងសេចក្តីណែនាំនានារបស់ **គ.ជ.អ.ប.**។

**មាត្រា ១៤.-**

**គ.ជ.អ.ប.** និងក្រសួង ស្ថាប័ននានាត្រូវធានាឲ្យមានសង្គតិភាពក្នុងការពិនិត្យមើលមុខងារឡើងវិញនៅក្នុងវិស័យទាំងឡាយណាដែលមានការពាក់ព័ន្ធនឹងក្រសួង ស្ថាប័នលើសពីមួយ និងត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នទាំងនេះ ព្រមទាំងជាមួយនឹងអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិនានាផ្សេងទៀត។

**មាត្រា ១៥.-**

នៅពេលដែលមុខងារណាមួយ ត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិនោះ ដំណើរការពិនិត្យមើលមុខងារឡើងវិញក៏ត្រូវកំណត់ផងដែរពីធនធានដែលត្រូវផ្ទេរជាមួយនឹងមុខងារ ព្រមជាមួយនឹងផែនការអភិវឌ្ឍន៍សមត្ថភាព ដែលអាចជាតម្រូវការចាំបាច់ដើម្បីធានាដល់ការចាត់ចែង ការគ្រប់គ្រង និងការអនុវត្តមុខងារនិងធនធានទាំងនោះ។

**មាត្រា ១៦.-**

ក្រសួង ស្ថាប័ននានាត្រូវកំណត់អំពីតួនាទីនិងការទទួលខុសត្រូវរបស់ខ្លួន បន្ទាប់ពីមុខងារត្រូវបានផ្ទេរ។

ការកំណត់អំពីតួនាទីនិងការទទួលខុសត្រូវរបស់ខ្លួនទាំងនេះ រួមមានការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយ ការរៀបចំបទដ្ឋាន ការគ្រប់គ្រង ការតាមដានត្រួតពិនិត្យ ព្រមទាំងការកំណត់ពីតម្រូវការនៃការអភិវឌ្ឍសមត្ថភាពនានាដែលពាក់ព័ន្ធនឹងតួនាទីនិងការទទួលខុសត្រូវទាំងនេះ។

**មាត្រា ១៧.-**

**គ.ជ.អ.ប.** ត្រូវចេញសេចក្តីណែនាំស្តីពីការពិនិត្យមើលមុខងារឡើងវិញសម្រាប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ធ្វើជាមូលដ្ឋានក្នុងការពិនិត្យមើលមុខងាររបស់ខ្លួនឡើងវិញ។

បន្ទាប់ពីបានពិនិត្យមើលឡើងវិញនូវមុខងាររបស់ខ្លួន ក្រសួង ស្ថាប័នត្រូវធ្វើរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញ ព្រមទាំងផែនការអភិវឌ្ឍន៍សមត្ថភាពនានាជូន **គ.ជ.អ.ប.** ដើម្បីពិនិត្យនិងសម្រេច។

## ផ្នែកទី៤
## ការអភិវឌ្ឍសមត្ថភាពដើម្បីទទួលមុខងារនិងធនធាន

**មាត្រា ១៨.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវទទួលខុសត្រូវក្នុងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនិងធនធានក្នុងពេលវេលាមួយសមស្រប ដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ **គ.ជ.អ.ប.** ស្របតាមមាត្រា២៣៥នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ១៩.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាព ដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលបាននូវមុខងារ មានសមត្ថភាពក្នុងការគ្រប់គ្រង

ចាត់ចែង និងអនុវត្តមុខងារនិងធនធានទាំងនោះឲ្យបានស្មើឬលើសកម្រិតបទដ្ឋានដែលមាននាពេលបច្ចុប្បន្ន។

**មាត្រា ២០.-**

ការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពទាំងនេះ ត្រូវធ្វើឡើងដោយមានកិច្ចសហការ និងមានការពិគ្រោះយោបល់រវាងក្រសួងស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ផ្នែកទី៥

## ការផ្ទេរមុខងារ ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

**មាត្រា ២១.-**

ការប្រគល់មុខងារឬការធ្វើប្រតិភូកម្មមុខងារ ត្រូវធ្វើឡើងដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ស្របតាមមាត្រា២៣៨នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ២២.-**

ការផ្ទេរមុខងារឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងស្របតាមមាត្រា២៣៣ ដល់មាត្រា២៤០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ការផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តមុខងារដែលត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងស្របតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី៥ ផ្នែកទី៦នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងជំពូកទី៣ ផ្នែកទី២នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ការផ្ទេរទ្រព្យសម្បត្តិសម្រាប់ការអនុវត្តមុខងារដែលត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងស្របតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី៥ ផ្នែកទី៧នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងស្របតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី៤នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ២៣.-**

**គ.ជ.អ.ប**. ត្រូវពិនិត្យមើលសេចក្តីព្រាងច្បាប់ សេចក្តីព្រាងព្រះរាជក្រឹត្យ សេចក្តីព្រាងអនុក្រឹត្យ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលកំណត់អំពីការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថាសេចក្តីព្រាងច្បាប់ សេចក្តីព្រាងព្រះរាជក្រឹត្យ សេចក្តីព្រាងអនុក្រឹត្យ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តទាំងនេះ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យនេះ។

**មាត្រា ២៤.-**

ការផ្ទេរមុខងារឲ្យទៅដល់ឃុំ សង្កាត់ ត្រូវលើកលែងចំពោះវិស័យទាំងឡាយដូចមានចែងនៅក្នុងមាត្រា៤៥នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ការផ្ទេរមុខងារឲ្យទៅដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវលើកលែងចំពោះវិស័យនិងមុខងារទាំងឡាយដែលត្រូវបានបម្រុងទុកផ្តាច់មុខសម្រាប់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ។

**មាត្រា ២៥.-**

ដំណើរការនិងនីតិវិធីនៃការផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារដែលត្រូវផ្ទេរ ត្រូវកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាសស្តីពីការផ្ទេរមុខងារនោះ។

## ផ្នែកទី៦

## ស្ថាប័នទទួលបន្ទុកអនុវត្ត

**មាត្រា ២៦.-**

**គ.ជ.អ.ប.** ដោយមានជំនួយពីអនុគណៈកម្មាធិការមុខងារនិងធនធាន និងលេខាធិការដ្ឋាន **គ.ជ.អ.ប.** ទទួលខុសត្រូវរួមចំពោះរាជរដ្ឋាភិបាលលើដំណើរការពិនិត្យមើលឡើងវិញនូវមុខងារនិងដំណើរការផ្ទេរមុខងារនិងធនធានស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**គ.ជ.អ.ប.** ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ស្តីពីវឌ្ឍនភាពនៃដំណើរការពិនិត្យមើលឡើងវិញនូវមុខងារនិងការផ្ទេរមុខងារនិងធនធាន។

ក្រសួង ស្ថាប័នដែលអនុវត្តការផ្ទេរមុខងារនិងធនធាន ត្រូវធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃដំណើរការនៃការអនុវត្តការផ្ទេរមុខងារនិងធនធានរបស់ខ្លួនជូន **គ.ជ.អ.ប.**។

**មាត្រា ២៧.-**

ក្រសួង ស្ថាប័ន ត្រូវទទួលខុសត្រូវជាចម្បងចំពោះ **គ.ជ.អ.ប.** លើដំណើរការរៀបចំបញ្ជីវិភាគមុខងារ ការពិនិត្យមើលឡើងវិញនូវមុខងារ និងដំណើរការផ្ទេរមុខងារនិងធនធាន។

**មាត្រា ២៨.-**

រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការចូលរួមចំណែកជួយគាំទ្រដល់ដំណើរការពិនិត្យមើលឡើងវិញនូវមុខងារដែលត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលរបស់ខ្លួន។

**មាត្រា ២៩.-**

រដ្ឋបាលរាជធានីនិងរដ្ឋបាលក្រុង ត្រូវពិនិត្យមើលមុខងាររបស់ខ្លួនឡើងវិញស្របតាមគោលការណ៍ដែលមានចែងនៅក្នុងមាត្រា៥ មាត្រា៦ និងមាត្រា៧នៃអនុក្រឹត្យនេះ ដើម្បីកំណត់អំពីមុខងារដែលអាចធ្វើប្រតិភូកម្មឲ្យទៅដល់រដ្ឋបាលខណ្ឌនិងរដ្ឋបាលសង្កាត់ ដោយមានភ្ជាប់ជាមួយនឹងការផ្ទេរធនធានសមស្រប។

## ផ្នែកទី៧

## យន្តការគាំទ្រ

**មាត្រា ៣០.-**

**គ.ជ.អ.ប.** ត្រូវធានាថា ការផ្ទេរមុខងារនិងធនធានត្រូវបានធ្វើឡើងតាមលក្ខណៈជាប្រព័ន្ធ តាមដំណាក់កាល មានសនិទានភាព ការសម្របសម្រួល ការពិគ្រោះយោបល់ តម្លាភាព និងប្រកបដោយសមធម៌។

**មាត្រា ៣១.-**

អនុគណៈកម្មាធិការមុខងារនិងធនធាន មានភារកិច្ចជួយលើការងារសម្របសម្រួល ពិគ្រោះយោបល់ ព្រមទាំងផ្ដល់អនុសាសន៍ដល់ **គ.ជ.អ.ប.** លើការងារទាំងអស់ដែលពាក់ព័ន្ធនឹងភារកិច្ចនិងការទទួលខុសត្រូវរបស់ **គ.ជ.អ.ប.** ក្នុងការកំណត់និងការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

លេខាធិការដ្ឋាន **គ.ជ.អ.ប.** ទទួលខុសត្រូវក្នុងការជួយអនុគណៈកម្មាធិការមុខងារនិងធនធាន និង **គ.ជ.អ.ប.** ផ្នែកបច្ចេកទេស ការសម្របសម្រួល ការពិគ្រោះយោបល់ ព្រមទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ដំណើរការផ្ទេរមុខងារនេះ។

# ជំពូកទី៣

# អន្តរប្បញ្ញត្តិ

## ផ្នែកទី១

## ដំណើរការផ្ទេរមុខងារនិងធនធានសម្រាប់វិស័យឬកិច្ចការអាទិភាព

**មាត្រា ៣២.-**

នៅដំណាក់កាលពីឆ្នាំ២០១២ដល់ឆ្នាំ២០១៣ **គ.ជ.អ.ប.** ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវផ្ដល់អាទិភាពដល់ដំណើរការផ្ទេរមុខងារក្នុងវិស័យឬកិច្ចការមួយចំនួនដូចខាងក្រោមៈ

- កសិកម្ម
- អប់រំ
- ព្រៃឈើ ជលផល ធនធានធម្មជាតិ និងបរិស្ថាន
- សុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជន រួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច
- ឧស្សាហកម្មនិងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច
- ការប្រើប្រាស់ដីធ្លី
- ការងារសុរិយោដីនិងការងារសំណង់
- ការផលិតនិងការចែកចាយអគ្គិសនី
- ការគ្រប់គ្រងទឹក
- តម្រូវការពិសេសឬតម្រូវការដែលបានកំណត់ជាក់លាក់សម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយគិតទាំងវិស័យទេសចរណ៍ តំបន់ប្រវត្តិសាស្ត្រ និងកេរដំណែលវប្បធម៌ផងដែរ
- សង្គមកិច្ច
- អភិវឌ្ឍន៍ជនបទ

ព្រមទាំងត្រូវយកចិត្តទុកដាក់ផ្តល់ការគាំទ្រលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ មធ្យោបាយ និងសម្ភារៈចាំបាច់ដើម្បីចាត់ចែងការទទួលខុសត្រូវលើមុខងារដែលបានប្រគល់និងធ្វើប្រតិភូកម្មខាងលើនេះ។

**មាត្រា ៣៣.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវលើមុខងារដែលស្ថិតនៅក្នុងចំណោមវិស័យឬកិច្ចការអាទិភាពដែលបានកំណត់ក្នុងមាត្រា៣២ខាងលើនេះ ត្រូវបញ្ចប់ការធ្វើបញ្ជីវិភាគមុខងារនិងការពិនិត្យមើលមុខងារឡើងវិញ ហើយដាក់របាយការណ៍ស្តីពីការធ្វើបញ្ជីវិភាគមុខងារនិងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញទាំងនោះជូន **គ.ជ.អ.ប.** ដើម្បីពិនិត្យនិងសម្រេចយ៉ាងយូរនៅចុងឆ្នាំ២០១២។

ចំពោះក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធនឹងវិស័យឬកិច្ចការអាទិភាពខាងលើត្រូវអនុវត្តដំណើរការផ្ទេរមុខងារ ដោយភ្ជាប់ជាមួយការផ្ទេរធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានផ្សេងទៀតដែលចាំបាច់និងសមស្របទៅតាមដំណាក់កាលៗ យ៉ាងយូរនៅក្នុងឆ្នាំ២០១៣ បន្ទាប់ពីទទួលបានការឯកភាពពី **គ.ជ.អ.ប.** លើរបាយការណ៍ស្តីពីការធ្វើបញ្ជីវិភាគមុខងារនិងរបាយការណ៍ស្តីពីការពិនិត្យមើលមុខងារឡើងវិញរបស់ខ្លួន។

**មាត្រា ៣៤.-**

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលមិនស្ថិតនៅក្នុងវិស័យឬកិច្ចការអាទិភាពខាងលើ ត្រូវអនុវត្តទៅតាមដំណើរការរៀបចំធ្វើបញ្ជីវិភាគមុខងារនិងការពិនិត្យមើលឡើងវិញនូវមុខងារដូចគ្នានឹងក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលស្ថិតនៅក្នុងវិស័យឬកិច្ចការអាទិភាពដែរ និងដាក់ជូន **គ.ជ.អ.ប.** នូវរបាយការណ៍ស្តីពីការធ្វើបញ្ជីវិភាគមុខងារនិងការពិនិត្យមើលមុខងារឡើងវិញសម្រាប់ការផ្ទេរមុខងារ យ៉ាងយូរនៅក្នុងឆ្នាំ២០១៣។

**មាត្រា ៣៥.-**

ពេលវេលា ដំណាក់កាលនីមួយៗ និងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលត្រូវចាប់ផ្តើមអនុវត្តដំណើរការផ្ទេរមុខងារនិងធនធាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ជ.អ.ប.**។

## ផ្នែកទី២
## ការផ្ទេរធនធានមនុស្ស

**មាត្រា ៣៦.-**

ក្នុងអំឡុងពេលដែលមិនទាន់មានច្បាប់ឬបទប្បញ្ញត្តិស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដំណើរការ និងនីតិវិធីនៃការផ្ទេរធនធានមនុស្សសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ ត្រូវកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាសស្តីពីការផ្ទេរមុខងារនិងធនធាននោះ និងស្របតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី៥ ផ្នែកទី៨នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ៣៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៣៨*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*